JobAccess

Driving disability employment

# បណ្ណព័ត៌មាន
# មានមូលនិធិសំរាប់និយោជក

មូលនិធិឧបត្ថម្ភការងារ (Employment Assistance Fund) (EAF) ផ្តល់ការឧបត្ថម្ភខាងហិរញ្ញវត្ថុដល់មនុស្សពិការ ឬនិយោជករបស់ពួកគេ ក្នុង ការបង់ថ្លៃកែនានាដែលពាក់ព័ន្ធនឹងការងារ និងការទិញសំភារៈ និងសេវានានា។

មូលនិធិនេះសំរាប់ជួយដល់បណ្តាជនដែលមានពិការភាពដែលកំពុងបំពេញការងារ ព្រមទាំងអ្នកដែលត្រូវការជំនួយឧបត្ថម្ភដើម្បីស្វែងរក និងត្រៀមខ្លួនសំរាប់ការងារ ។

ឧទារហណ៍មួយចំនួនដែលមូលនិធិឧបត្ថម្ភការងារអាចប្រើប្រាស់បានមានដូចជា ៖

- ការកែទីកន្លែងធ្វើការ និងឧបករណ៍សំភារៈផ្សេងៗ ដូចជាបច្ចេកវិទ្យា ជំនួយ ឧបករណ៍អេឡិចត្រូនិច និងទំនាក់ទំនងទូរគមនាគមន៍
- ឧបករណ៍បច្ចេកវិទ្យាទូរគមនាគមន៍
- ការបកប្រែភាសាគ Auslan (Australian sign language)
- កម្មវិធីកុំព្យូទ័រ និងការតំលើងកម្មវិធីចុងក្រោយធ្វើអោយប្រសើរឡើង
- ការកែតម្រូវទីកន្លែងធ្វើការ
- ការកែយានយន្តធ្វើដំណើរសំរាប់ការងារ
- ការបណ្តុះបណ្តាលឲ្យមានការយល់ដឹងអំពីភាពថ្លង់
- ការបណ្តុះបណ្តាលឲ្យមានការយល់ដឹងអំពីពិការភាព និង
- សេវាគាំទ្រនានាពីអ្នកជំនាញដែលទាក់ទងនឹងការងារសំរាប់បុគ្គលិកដែលមានបញ្ហាសុខភាព ផ្លូវចិត្ត ឬមានវិបល្លាសក្នុងការសិក្សា

## ការឧបត្ថម្ភប្រាក់បៀវត្ស

ការឧបត្ថម្ភប្រាក់បៀវត្សផ្តល់ការលើកទឹកចិត្តជាប្រាក់ដល់បណ្តានិយោជកដែលកំពុងផ្តល់ការងារដល់ប្រជាជនដែលមានពិការភាព និងអ្នកធ្វើការដែលមានវ័យចំណាស់ ។

ជានិយោជកម្នាក់ អ្នកអាចមានសិទ្ធិទទួលជំនួយហិរញ្ញវត្ថុដើម្បីឧបត្ថម្ភការងាររបស់បុគ្គលិកដែលមានពិការភាព តាមរយៈកម្មវិធីជំនួយឧបត្ថម្ភប្រាក់បៀវត្សនៃសេវាការងារសម្រាប់ជនពិការ (Disability Employment Services) (DES) ឬ ចាប់ផ្តើមឡើងវិញសំរាប់អ្នកមានអាយុច្រើន។

សំរាប់ពត៍មានបន្ថែមស្តីអំពីមូលនិធិឧបត្ថម្ភការងារ (EAF) ឬកម្មវិធីឧបត្ថម្ភប្រាក់បៀវត្ស សូមបើកមើលគេហទំព័រ www.jobaccess.gov.au ឬក៏ទាក់ទងមកអ្នកផ្តល់យោបល់របស់JobAccess 1800 464 800 - ការទាក់ទងតាមទូរសព្ទ័ដៃត្រូវគេគិតថ្លៃ។

Australian Government

JobAccess is the national hub for workplace and employment information for people with disability, employers and service providers.

1800 464 800 www.jobaccess.gov.au